# រឿងប្រេតទាំង៤នាក់

( ចាក បេ. ខុ. )

( អំពើទុច្ចរិតជាពូជនៃពៀរទាំងឡាយ )

កាលព្រះសម្ពុទ្ធគង់នៅវត្តជេតពននាក្រុងសាវត្ថី មានឈ្មួញម្នាក់ជួញស្រូវបាន យកសំដីស្រូវ ( សង្កៀបស្រូវ ) លាយនិងស្រូវរាល់លក់ឲ្យអ្នកដទៃ ។ ឯកូនប្រុស របស់គាត់ មើលងាយមាតាបិតារបស់ខ្លួន យកខ្សែព្រ័ត្រដាក់លើក្បាលមាតាបិតា ឯកូនប្រសារស្រី លួចលាក់សាច់ងៀតស៊ីតែម្នាក់ឯង មិនឲ្យស្វាមី និងមាតាបិតា បរិភោគឡើយ ។ ចំណែកភរិយារបស់ឈ្មួញនោះ ជាមនុស្សកំណាញ់ សំដីអាក្រក់ ឃើញពួកស្មូមទៅសុំអ្វីៗ ដៀលស្តីថាឲ្យ ស្មូមនោះទៅស៊ីមូត្រលាមក ។

ក្នុងពេលក្រោយមក ជនទាំង៤នាក់នោះ ស្លាប់បន្តរបន្ទាប់គ្នា តាមវ័យរបស់ខ្លួន ទៅកើតជាប្រេត នៅចន្លោះភ្នំគិជ្ឈកូដ ប្រេតទាំង៤រងទុក្ខវេទនាផ្សេងៗ គ្នា គឺ ប្រេតជាឈ្មួញកម្មបណ្តាលឲ្យមានសំដីស្រូវដែកឆេះក្រហមគរ ជាគំនរ ប្រេត នោះចេះតែកើបដាក់លើក្បាល ឆេះក្តៅស្រែកទ្រហោយំជានិច្ចឥតស្រាកស្រាន្ត ។ ប្រេតកូនប្រុសរបស់គាត់ ផលកម្មបណ្តាលឲ្យមានញញួរដែកឆេះក្រហមកាន់នឹង ដៃ វាយសំពងក្បាល់ខ្លួនឯងបែកឈាមហូរស្រោចពេញខ្លួន ស្រែកថ្ងូរឥតស្រាក ស្រាន្ត ។ ប្រេតកូនប្រសារស្រីរបស់គាត់មានក្រចកវែងៗ ខ្វាហែកសាច់ចំឡុក របស់ខ្លួនយកមកស៊ី ស្រែកយំឥតស្រាកស្រាន្ត ។ ឯប្រេតភរិយារបស់ឈ្មួញនោះ ផលកម្មបណ្តាលឲ្យកើតរណ្តៅមូត្រលាមកស្អុយរលួយ ចុះទៅកើបស៊ីមួយថ្ងៃៗ ដរាបដល់យប់ ។ ដល់ថ្ងៃវិញមិនចេះឆ្អែត ចេះតែឃ្លានក្រៃលែងឥតឧបមា ។

ថ្ងៃមួយព្រះមហាមោគ្គល្លាន និមន្តទៅភ្នំគិជ្ឈកូដ បានឃើញប្រេតទាំង៤ កំពុងរង ទោសវេទនា ក៏សួរបុព្វកម្មរបស់ប្រេតបានសព្វគ្រប់ហើយ និមន្តមកកាន់ វត្តជេតពន ក្រាបទូលរឿងប្រេតនោះចំពោះព្រះមានព្រះភាគ ។ ប្រជុំបរិស័ទ

ហើយសំដែងធម៌ទេសនា ប្រារព្ធយករឿងប្រេតនោះជាហេតុ ដល់ទីបំផុតនៃព្រះធម៌ទេសនា ទ្រង់ប្រកាសអំពីអរិយសច្ច៤ ប្រការ ពុទ្ធបរិស័ទទាំងមនុស្សនិងទេវតា បានសម្រេចមគ្គផលតាមនិស្ស័យរៀងៗខ្លួន ។